# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ០៥០ គ.ជ.ប. ស.ណ.ន

# សេចក្តីណែនាំ
## ស្តីពី
## ការពង្រឹង សន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយ ក្នុងការិយាល័យបោះឆ្នោត និង ការិយាល័យរាប់សន្លឹកឆ្នោត ក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០២៤

ដើម្បីឱ្យដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤ ប្រព្រឹត្តទៅដោយរលូន និងធានាបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ របៀបរៀបរយ និងបរិយាកាសស្ងប់ស្ងាត់ល្អ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមណែនាំដល់ប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) និងប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ) ដូចខាងក្រោម ៖

### ១- អ្នកដែលមានសិទ្ធិចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

#### ក. អ្នកដែលមានសិទ្ធិចូលក្នុងការិយាល័យបោះឆ្នោត

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម ៖

- មន្ត្រីបោះឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប
- ភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលបានអនុញ្ញាត ហើយមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គធ.ខប
- អ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ឬដោយ គធ.ខប
- អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប
- អ្នកដែលមានសិទ្ធិបោះឆ្នោត ហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ
- ជនដែលអមដំណើរអ្នកបោះឆ្នោតជាជនមានពិការភាព តាមលក្ខខណ្ឌដូចមានចែងក្នុង ច.ប.ត.រ
- ភ្នាក់ងារសន្តិសុខបោះឆ្នោត និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.ប ធ្វើសំណូមពរក្នុងករណីចាំបាច់។

#### ខ. អ្នកដែលមានសិទ្ធិចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម ៖

- មន្ត្រីរាប់សន្លឹកឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប
- ភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលបានអនុញ្ញាត ហើយមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គធ.ខប



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីម៉ែល : info@nec.gov.kh

- អ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ឬដោយ គធ.ខប
- អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប
- ភ្នាក់ងារសន្តិសុខបោះឆ្នោត និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.រ ធ្វើសំណូមពរក្នុងករណីចាំបាច់។

**២- អ្នកដែលមិនមានសិទ្ធិចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត**

មិនត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុង នូវជនទាំងឡាយដែលមិនស្ថិតក្នុងចំណុចទី១ ខាងលើរួមទាំង៖ សមាជិកព្រឹទ្ធសភា អ្នកតំណាងរាស្ត្រ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិករាជរដ្ឋាភិបាល ថ្នាក់ដឹកនាំគណបក្សនយោបាយគ្រប់លំដាប់ថ្នាក់ អាជ្ញាធរដែនដី អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ លើកលែងតែសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានសិទ្ធិបោះឆ្នោតហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។

**៣- អំពីកិច្ចសហការ និងការអនុវត្ត**

គធ.ខប និង គ.ក.ប/គ.ក.រ ត្រូវសហការជាមួយកម្លាំងសន្តិសុខបោះឆ្នោតតាមមូលដ្ឋាន និងតាមការិយាល័យនីមួយៗរៀងៗខ្លួន ដើម្បីធានាឱ្យបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

គធ.ខប ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងមុខតំណែងនៅក្នុងក្របខណ្ឌក្រុង ស្រុក ខណ្ឌនីមួយៗ។

ទទួលបានសេចក្តីណែនាំនេះ ប្រធាន គធ.ខប និងប្រធាន គ.ក.ប/គ.ក.រ ត្រូវយកចិត្តទុកដាក់សហការអនុវត្តឱ្យមានប្រសិទ្ធភាព និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៦កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២៤
**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

ប្រាជ្ញ ចន្ទ

**កន្លែងទទួល ៖**
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- លេខាធិការដ្ឋាន នៃ គ.ស.អ
- គណៈអភិបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងជាគណៈបញ្ជាការឯកភាពរដ្ឋបាល
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
"ដើម្បីជូនជ្រាប ផ្សព្វផ្សាយ និងសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ